**Cambodian - Infantile Seborrhoeic Dermatitis Cradle Cap**

ជម្ងឺរលាក



# ជម្ងឺកមក្បាល

## ចំណុចសំខាន់ៗ

- ជម្ងឺកមក្បាលមិនមែនជាររមាស់ទេ ហើយមិនជាអំពល់អ្វីដល់ទារកឡើយ
- ជៀសវាងសាប៊ូ ដោយហេតុថាវាអាចធ្វើឲ្យក្រហាយដល់ការរលាកស្បែក
- ប្រើប្រេងដាក់ត្រាំក្នុងទឹកដែលពុំមានក្លិនក្រអូប ជំនួសសាប៊ូ
- ប្រើក្រែមការពារកុំឲ្យស្ងួតស្បែក ដូចជាក្រែម aqueous ឬក្រែម sorbolene
- ប្រើប្រេងអូលីវលាបលើស្បែកលលាដ៍ក្បាលឲ្យបានច្រើនដង ក្នុងមួយអាទិត្យដើម្បីយកក្រមរចេញ
- ជម្ងឺកមក្បាលជាបាត់អស់ទៅវិញក្នុងចំណោមទារកតូចៗភាគច្រើន នៅពេលចូលដល់អាយុប្រហែល២ខែ ឬច្រើនជាងនេះ។

## តើវាជាអ្វី?

ជម្ងឺកមក្បាលគឺជាជម្ងឺរលាកស្បែកទូទៅ ដែលអាចទាក់ទងនឹងស្បែកលលាដ៍ក្បាល និងផ្នត់ផងខ្លួនរបស់កុមារតូចៗ។ មិនដូចជម្ងឺត្រអកកុមារឡើយ ជម្ងឺកមក្បាលមិនរមាស់ទេ។ នៅក្នុងចំណោមទារកទើបនឹងកើតភាគច្រើន វាតែងបាត់ទៅវិញនៅក្នុងអាយុពីរខែ។ ការនេះខុសពីជម្ងឺត្រអកកុមារ ដែលចេះតែកើតមានបន្ទាប់ពីអាយុពីរខែ ហើយចេះតែកើតមានតទៅទៀត។ សណ្ឋានទូទៅ ហើយមិនសូវខ្លាំងដែលប៉ះពាល់ស្បែកលលាដ៍ក្បាលកូនក្មេង ត្រូវបានគេហៅថាជម្ងឺកមក្បាល។

## តើវាកើតនៅកន្លែងណា?

នៅក្នុងទារកភាព កន្លែងដែលប៉ះពាល់ទូទៅជាងគេគឺស្បែកលលាដ៍ក្បាលដែលគេឃើញខ្លាញ់ក្រមរច្បាស់ ពណ៌សលឿងៗបន្តិច ដុះក្រាស់នៅជាប់សក់ ឬស្បែកលលាដ៍ក្បាល។ វាអាចរាលដាលចុះមកដល់កណ្តាលមុខ ពីក្រោយត្រចៀក ឬនៅលើកញ្ចឹងក។ វាអាចកើតមាននៅកន្លែងពាក់កន្ទប និងក្លៀកផងដែរ ដែលមានពណ៌ក្រហមច្រើនជាងក្រមរ ហើយជាញឹកញយមានជាប់ទាក់ទិននឹងផ្នត់គ្រលៀន។ ជម្ងឺកមក្បាលដែលប៉ះពាល់ដល់ផ្នត់គ្រលៀន ជាទូទៅអាចក្លាយទៅជាជម្ងឺជ្រាំង។

## តើគេព្យាបាលវាដោយរបៀបណា?

ប្រសិនបើវាជាជម្ងឺកមក្បាលបន្តិចបន្តួច គេអាចព្យាបាលវាជាមួយក្រែមធ្វើឲ្យសើមស្បែកដូចជាក្រែម aqueous ឬក្រែម sorbolene ឬប្រេងអូលីវក៏បានដែរ។ ប្រសិនបើវាធ្ងន់ធ្ងរខ្លាំងគេអាចលាយប្រេងទាំងនេះជាមួយក្រែម salicylic acid cream (ក្រែមជាតិអាស៊ីដសាលីស៊ីលិក) ឬក្រែម cortisone cream (ក្រែមខទីហ្សូន) មិនសូវខ្លាំងដែលត្រូវបានណែនាំដោយឱសថការី ឬវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក។

ជម្ងឺកមក្បាលនៅកន្លែងពាក់កន្ទប ជាញឹកញយអាចព្យាបាលដោយលាយជាមួយប្រេងដាក់ត្រាំក្នុងទឹក ហើយប្រើក្រែមជំនួសសាប៊ូដុំ ដូចជាប្រេង aqueous cream ឬប្រេង emulsifying ointment (ប្រេងលាបស្បែកដែលធ្វើឲ្យរាវ)។ ប្រេង cortisone cream ដែលមិនសូវខ្លាំងអាចត្រូវបានណែនាំដោយវេជ្ជបណ្ឌិត សំរាប់ប្រើជាមួយក្រែមបន្ថែមដើម្បីព្យាបាលជម្ងឺជ្រាំង។ ប្រសិនបើកើតមានកន្ទួលនៅពីលើមុខ គេអាចប្រើក្រែម cortisone cream ដែលមិនសូវខ្លាំងចំនួនមួយថ្ងៃ ឬពីរថ្ងៃ បន្ទាប់មកត្រូវប្រើជាមួយក្រែមធ្វើឲ្យសើមស្បែកឲ្យបានទៀងទាត់។

## ពត៌មានបន្ថែមទៀត

- គិលានុបដ្ឋាយិកាមើលថែទាំសុខភាពមាតា និងកុមារ
- ឱសថការីរបស់លោកអ្នក
- វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក
- វេជ្ជបណ្ឌិតឯកទេសជម្ងឺសើរស្បែក

© 2002, Department of Dermatology, St. Vincent's Hospital Melbourne, Victoria Parade, Fitzroy, Victoria 3065 Australia.